# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

********

# សុន្ទរកថាបើកកម្មវិធី
# របស់ឯកឧត្តម ហុង សុហ្វារ
# អគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
# ក្នុងសិក្ខាសាលាស្តីពី «ធនាគារ អេស៊ីលីដា ភីអិលស៊ី
# គ្រោងនឹងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ»
# រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០២០

៙៙✹៚៚

- លោកបណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី
- លោក ហាន់ ក្យុង ធៃ អគ្គនាយក ក្រុមហ៊ុនមូលបត្រ យាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី
- លោក ហា ចុងវ៉ន អគ្គនាយករង ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- លោក ព្រំ វិសុទ្ធ អគ្គនាយក ក្រុមហ៊ុនមូលបត្រអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី
- លោកស្រី ម៉ារ អមរា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ ធនាគារអេស៊ីលីដា ភីអិលស៊ី
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី!

ថ្ងៃនេះ តំណាងឱ្យផ្សារមូលបត្រកម្ពុជា ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលសិក្ខាសាលានេះត្រូវបានរៀបចំឡើង ដោយមានការចូលរួមយ៉ាងច្រើនកុះករពីសំណាក់បុគ្គលិក-មន្ត្រីរបស់ធនាគារ អេស៊ីលីដា និងសាធារណជនយ៉ាងច្រើនកុះករ។ សិក្ខាសាលានេះនឹងជួយឱ្យវិនិយោគិនអាចត្រៀមខ្លួនដើម្បីចូលទីផ្សារភាគហ៊ុន ដោយផ្តល់នូវព័ត៌មានចាំបាច់នានា ដើម្បីជាទុនក្នុងការវិនិយោគ និងការពារហានិភ័យនានា។ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ដល់ធនាគារ អេស៊ីលីដា ដែលបានផ្តួចផ្តើមរៀបចំកម្មវិធីនាថ្ងៃនេះ ក៏ដូចជាថ្ងៃទី ១៥ និង ថ្ងៃទី ១៨ ខែមករានេះ ដើម្បីជួយលើកកម្ពស់ការយល់ដឹងរបស់វិនិយោគិន។

ជាក់ស្តែង ការវិនិយោគនៅក្នុងផ្សារមូលបត្រ អាចធ្វើឡើងនៅក្នុងផ្សារដំបូង នៅពេលក្រុមហ៊ុនបោះផ្សាយមូលបត្រ និងនៅផ្សារបន្ទាប់ នៅពេលដែលមូលបត្រត្រូវបានជួញដូរនៅCSX រវាងវិនិយោគិន និង

វិនិយោគិន។ វាគ្និទរបស់នៅនឹងធ្វើបទបង្ហាញជូនលោកអ្នកពីដំណើរការនៃការវិនិយោគ និងអត្ថប្រយោជន៍ខុសគ្នានៃការវិនិយោគ នៅក្នុងទាំងពីរដំណាក់កាលនេះ។ ខ្ញុំជឿជាក់ថា សិក្ខាសាលានាថ្ងៃនេះនឹងផ្តល់ជាពុទ្ធិល្អៗ ដល់សិក្ខាកាមរបស់យើង ដើម្បីទទួលបានជោគជ័យទាំងអស់គ្នាក្នុងវិស័យមូលបត្រ ព្រោះការវិនិយោគក្នុងវិស័យមូលបត្រមិនមែនជាល្បែងស៊ីសង ដែលត្រូវតែមានអ្នកខាត ដើម្បីឱ្យអ្នកផ្សេងចំណេញនោះទេ។ ការវិនិយោគលើក្រុមហ៊ុន ដែលល្អ នឹងផ្តល់ភាគលាភខ្ពស់ និងមានថ្លៃភាគហ៊ុនកើនឡើង ដែលនឹងធ្វើឱ្យមានការចំណេញទាំងអស់គ្នា។ បន្ទាប់ពីសិក្ខាសាលានៅថ្ងៃនេះ វិនិយោគិនដែលនៅមានចម្ងល់ ឬចង់យល់ដឹងបន្ថែម អាចបន្តចូលរួមសិក្ខាសាលាបន្តបន្ទាប់ ដែលផ្សារមូលបត្រកម្ពុជានឹងរៀបចំឡើងជារៀងរាល់ខែ លើប្រធានបទផ្សេងៗគ្នា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ដោយសារធនាគារអេស៊ីលីដាមានភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងបំពេញគ្រប់លក្ខខណ្ឌអាចចុះបញ្ជីបាន ផ្សារមូលបត្រកម្ពុជាបានសម្រេចឯកភាពជាគោលការណ៍ លើពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅទីផ្សារគោលរបស់ ធនាគារ អេស៊ីលីដា នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩។ ដំណាក់កាលបន្ទាប់ ធនាគារនឹងស្នើសុំការឯកភាពបន្ថែមលើការបោះផ្សាយមូលបត្រពីខាងគណៈកម្មការមូលបត្រកម្ពុជា ដើម្បីបន្តនិតិវិធីប៊ុកបៀលឌីង និងដំណើរការបរិវិសកម្ម ដើម្បីអនុញ្ញាត្តិឱ្យវិនិយោគិនរបស់យើងអាចចាប់ផ្តើមវិនិយោគបានជាមួយធនាគារ អេស៊ីលីដា។

ការបោះផ្សាយមូលបត្ររបស់ធនាគារអេស៊ីលីដា នឹងក្លាយទៅជាគំរូដ៏ល្អមួយសម្រាប់ស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ក្នុងការប្រមូលទុនពីសាធារណជនក្នុងស្រុក ដើម្បីពង្រីកវិសាលភាពអាជីវកម្មរបស់ខ្លួនទាំងក្នុងប្រទេស និងក្នុងតំបន់។ ការចូលផ្សារហ៊ុនរបស់ធនាគារអេស៊ីលីដា នឹងធ្វើឱ្យធនាគារមួយនេះទទួលបានការទុកចិត្តកាន់តែខ្លាំងឡើងពីសំណាក់ប្រជាពលរដ្ឋខ្មែរ ដែលនឹងធ្វើឱ្យអាជីវកម្មរបស់ស្ថាប័នមួយនេះកាន់តែមានការគាំទ្រ និងមានការជឿជាក់កាន់តែខ្លាំងឡើង។

ការចុះបញ្ជីរបស់ធនាគារអេស៊ីលីដា ស្របពេល ដែលទីផ្សាររបស់យើងកំពុងតែចាប់ផ្តើមរីកចម្រើនខ្លាំងជាមួយនឹងការកើនឡើងយ៉ាងខ្លាំងនូវចំនួនវិនិយោគិនរហូតដល់ជាង ២២ពាន់នាក់ ហើយសន្ទស្សន៍ផ.ម.ក. កើនឡើង ប្រមាណ៥៨%នៅក្នុងឆ្នាំ ២០១៩។ បច្ចុប្បន្ននេះ យើងមានក្រុមហ៊ុនចំនួន ៧ ដែលកំពុងតែរៀបចំនិតិវិធីក្នុងការបោះផ្សាយ និងចុះបញ្ជីភាគហ៊ុន ឬសញ្ញាប័ណ្ណនៅក្នុងឆ្នាំ២០២០នេះ ហើយយើងរំពឹងថាចំនួននេះនឹងបន្តកើនឡើងទ្វេរដងនៅឆ្នាំបន្ទាប់ៗទៀត។ បន្ទាប់ពីការចុះបញ្ជីរបស់ធនាគារ អេស៊ីលីដា យើងក៏សង្ឃឹមថា ចំនួនវិនិយោគិនសកម្ម និងទំហំជួញដូរនៅលើទីផ្សារនឹងមានការកើនឡើងជាបន្តបន្ទាប់ផងដែរ ដែលជាកត្តាសំខាន់មួយក្នុងការទាក់ទាញការចុះបញ្ជី និងការវិនិយោគមកលើទីផ្សារបន្ថែមទៀត។

ធនាគារ អេស៊ីលីដា ជាអ្នកចូលរួមដ៏សំខាន់ក្នុងវិស័យមូលបត្រ ដោយធនាគារ អេស៊ីលីដា បានក្លាយជា

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ, ភ្នាក់ងារបញ្ជិកាមូលបត្រ និង ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ, ភ្នាក់ងារទូទាត់, បុត្រសម្ព័ន្ធរបស់ធនាគារ គឺអេស៊ីលីដា ស៊ីឃ្យូរីធី ជាក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ និងជាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលផងដែរ។ ភាពរីកចម្រើនរហូតមកដល់បច្ចុប្បន្នរបស់វិស័យមូលបត្រពិតជាមានការចូលរួមពីសំណាក់ ធនាគារ អេស៊ីលីដា យ៉ាងពិតប្រាកដ។ រហូតដល់បច្ចុប្បន្ននេះ ធនាគារ អេស៊ីលីដា បានសម្រេចចិត្តដ៏ត្រឹមត្រូវ ហើយការសម្រេចចិត្តនេះបានធ្វើឱ្យមាននូវការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់សាធារណជន ក៏ដូចជាវិនិយោគិនមានស្រាប់របស់យើង គឺការបោះផ្សាយ និងចុះបញ្ជីមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរអគុណដល់**បណ្ឌិត អ៊ិន ចាន់នី** និងក្រុមការងាររបស់ធនាគារ អេស៊ីលីដាទាំងអស់ ដែលបានខិតខំធ្វើឱ្យសិក្ខាសាលានាថ្ងៃនេះទទួលបានជោគជ័យ។ ខ្ញុំសូមជូនពរដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារទទួលបានជោគជ័យត្រចះត្រចង់ ដោយមានចំនួនអ្នកធ្វើបរិវិសកម្មច្រើន និងលក់អស់មូលបត្រ ដែលគ្រោងនឹងបោះផ្សាយទាំងអស់។ សូមគោរពជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងឱកាសឆ្នាំថ្មី ឆ្នាំ ២០២០នេះ ទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈ។ ខ្ញុំសូមអនុញ្ញាតិចូលរួមជាមួយ**បណ្ឌិត អ៊ិន ចាន់នី** ប្រកាសបើកសិក្ខាសាលាចាប់ពីពេលនេះតទៅ។

សូមអរគុណ!

**********